**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកទុក្ខ

**ជូនចំពោះ**
**លោក ជិន វណ្ណថា អគ្គនាយករង អគ្គនាយកដ្ឋានកិច្ចការទូទៅ**
**នៃក្រសួងមុខងារសាធារណៈ ព្រមទាំងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្ដីក្រៀមក្រំ និងសោកស្ដាយជាពន់ពេក ដោយបានទទួលដំណឹងថា **ឯកឧត្តម អ៊ុក ដាមរី** សមាជិកគណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល ដែលត្រូវជាឪពុកក្មេករបស់ **លោក ជិន វណ្ណថា** បានទទួលមរណភាពកាលពីថ្ងៃចន្ទ ១៥រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ០៥:១៨នាទីព្រឹក ក្នុងជន្មាយុ ៧០ឆ្នាំ ដោយរោគាពាធ។

ក្នុងបរិយាកាសប្រកបដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្ដែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្ដាយជាទីបំផុតជាមួយ **លោក ជិន វណ្ណថា** ព្រមទាំងក្រុមគ្រួសារ ចំពោះការបាត់បង់ដ៏ធំធេងដែលមិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ការបាត់បង់ **ឯកឧត្តម អ៊ុក ដាមរី** ជាការបាត់បង់នូវវៃស្សរជន និងធនធានមនុស្ស មួយរូប ដែលតែងតែបានពុះពារ លះបង់អស់កម្លាំងកាយ ចិត្ត ធនធាន បញ្ញាស្មារតី ក្នុងការបម្រើប្រទេសជាតិ រួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍជាតិមាតុភូមិនាពេលកន្លងមក។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម អ៊ុក ដាមរី** បានអញ្ជើញទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក ជិន វណ្ណថា** ព្រមទាំងក្រុមគ្រួសារ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ។

ថ្ងៃច័ន្ទ ១៥រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុន ម៉ានី** 

**ព្រុំ សុខា**